# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ  សាសនា  ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ១០៩៥/០៩ គ.ជ.ប

## សេចក្តីណែនាំ

**ស្តីពី កិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់**
**ក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០០៨**

<u>**យោង**</u>
- ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់នេះ
- ប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៨ ។

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០០៨ ត្រូវដំណើរការពីថ្ងៃទី ០១ ខែតុលា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨ ។ ក្នុងគោលបំណងឱ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៨ នេះ ប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខល្អ គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមណែនាំដល់ប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ដូចតទៅនេះ ៖

- ត្រូវធ្វើទំនាក់ទំនង និងសហការជាមួយគណៈបញ្ជាការឯកភាពខេត្ត ក្រុង ពិសេសស្នងការដ្ឋាននគរបាលខេត្ត ក្រុង អធិការដ្ឋាននគរបាលខណ្ឌ ស្រុក និងប៉ុស្តិ៍នគរបាលរដ្ឋបាល ដើម្បីពិនិត្យ និងចាត់វិធានការការពារសន្តិសុខ សុវត្ថិភាពឱ្យបានមធ្យ័ត និងតឹងរ៉ឹងបំផុត ។
- ត្រូវពង្រឹងកិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ នៅគ្រប់ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅក្នុងសាលាឃុំ សង្កាត់ ឬនៅតាមបណ្តាភូមិនានាក្នុងឃុំ សង្កាត់ ។
- ត្រូវចាត់ចែង តាមដានត្រួតពិនិត្យសភាពការណ៍ និងស្នើសុំអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ច ក្នុងករណីមានការអុកឡុករំខាន ការគំរាមកំហែង ឬអំពើល្មើសច្បាប់ ធ្វើឱ្យរាំងស្ទះដល់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៨ នេះ ។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់អនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៨

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

អ៊ឹម សួស្តី

**ចម្លងជូន ៖**

- អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- គណៈបញ្ជាការឯកភាពខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ